# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ផលប៉ះពាល់ពីការបំបែកកិច្ចដំណើរការនីតិវិធីចំពោះឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិទាមទារសំណងជាលក្ខណៈបុគ្គល

ដោយ អាន ហាញឌុល

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣

ប្រែសម្រួលដោយ លីម ជ័យទ័ត្ត

តាមរយៈការស្នើសុំរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានកំណត់រួចរាល់នូវបញ្ជីអាទិភាពស្តីពីគម្រោងសំណង ដែលស្ថិតនៅក្រោមការវិវឌ្ឍនៃសំណុំរឿង០០២/០១ ។ ទោះបីជាយ៉ាងណា ការដាក់ជូនបញ្ជីនេះ គឺកើតឡើងតំណាលគ្នានឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលសម្រេចមោឃភាពដីកាបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២របស់អង្គជំនុំជម្រះសាលាដំបូងជាផ្នែកតូចៗ ។ ជាមួយនឹងបញ្ហាមិនច្បាស់លាស់នៃសំណុំរឿង០០២/០១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរក្សាសិទ្ធិក្នុងការកំណត់សារជាថ្មីនូវសំណើសុំសំណងរបស់ខ្លួន ដោយអនុលោមតាមការសម្រេចចុងក្រោយស្តីពីវិសាលភាពនៃសំណុំរឿង០០២/០១ នៅពេលណាដែលមានសេចក្តីសម្រេចចេញមក ។

នៅក្នុងសំណុំរឿង០០២ ដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែលកំពុងរស់រានមានជីវិត មានជនរងគ្រោះជិតបួនពាន់នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសំណើសុំភាគច្រើនត្រូវបានទទួលយកតាមរយៈបណ្តឹងឧទ្ធរណ៍ ។ គួរកត់សម្គាល់ថា វិធានផ្ទៃក្នុងពុំបានទាមទារឲ្យមានទំនាក់ទំនងហេតុផលរវាងព្យសនកម្ម និងអង្គហេតុដែលត្រូវបានស៊ើបអង្កេតនោះទេ គឺវាតម្រូវឲ្យមានទំនាក់ទំនងហេតុ និងផលរវាងព្យសនកម្ម និងឧក្រិដ្ឋកម្មណាមួយដែលត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ ។ អង្គបុរេជំនុំជម្រះបានរកឃើញថា នៅក្នុងបរិបទនៃសំណុំរឿង០០២ :

> ទោះបីជាអង្គហេតុដែលត្រូវស៊ើបអង្កេតកំណត់ត្រឹមតែទៅលើតំបន់ ឬទីតាំងឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ ក៏ការកំណត់បទចោទនៃអង្គហេតុ.......បានរួមបញ្ចូលនូវឧក្រិដ្ឋកម្មដែលតំណាងឲ្យអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ ដែលត្រូវបានចោទប្រកាន់ថាជនត្រូវចោទបានធ្វើឡើងរួមគ្នា ក្នុងពេលអនុវត្តសហឧក្រិដ្ឋកម្មរួម ព្រមទាំងរួមបញ្ចូលឧក្រិដ្ឋកម្មដទៃទៀតដែលបានធ្វើឡើងប្រឆាំងប្រជាជន និងនៅទូទាំងប្រទេស ។

អង្គបុរេជំនុំជម្រះបានសម្រេចថា ហេតុដូច្នេះ ពុំមានភាពចាំបាច់ណាមួយសម្រាប់អ្នកដាក់ពាក្យសុំត្រូវបង្ហាញឲ្យឃើញពីភាពជាប់ទាក់ទងនៃព្យសនកម្មរបស់ពួកគេទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលមាននៅក្នុងដីកាដំណោះស្រាយនោះទេ គឺគ្រាន់តែបង្ហាញនូវឧទាហរណ៍ ដើម្បីចង្អុលបង្ហាញថាតើមន្ទីរ និងទីតាំងទាំងអស់នោះដើរតួនាទីយ៉ាងដូចម្តេចនៅទូទាំងប្រទេសកម្ពុជា ។ អ្វីដែលជាបញ្ហាគឺថា នៅក្នុងសំណុំរឿង ០០២ មានបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលរងគ្រោះពីការអនុវត្តគោលនយោបាយមួយ ឬច្រើននៃគោលនយោបាយឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទោះបីជាតំបន់ភាគច្រើននៅទូទាំងប្រទេសមិនត្រូវបានជ្រើសរើសមកធ្វើការស៊ើបអង្កេតក៏ដោយ ។

ក្រោយពីមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការបំបែកបទចោទប្រកាន់ដែលមាននៅក្នុងសំណុំរឿង០០២ ដោយរំពឹងថានឹងមានសវនាការលើសពីមួយដែលជំនុំជម្រះលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ។ សវនាការដំណាក់កាលដំបូង (០០២/០១) បានកំរិតមកត្រឹម ការផ្លាស់ទីនៅប្រជាជនដោយបង្ខំនៅតំណាក់កាលទី១ និងទី២ ដោយរាប់បញ្ចូលការជម្លៀសប្រជាជនដោយបង្ខំពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ រាល់គោលនយោបាយឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមមានអំពើប្រល័យពូជសាសន៍ ការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ ការបង្ខំឲ្យធ្វើការនៅតាមបណ្តាលសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ និងផ្លាស់ទីលំនៅដោយបង្ខំពីភមិភាគបូព៌ា ត្រូវបានដកចេញ ។ នៅក្នុងការធ្វើសេចក្តីសម្រេចបំបែកបទចោទប្រកាន់នេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីលែងចលរួមសវនាការជាលក្ខណៈបុគ្គល (ដូចដែលធ្លាប់មាននៅក្នុងសំណុំរឿង ០០១) ប៉ុន្តែត្រូវជំនួសមកជាការរួមជាក្រុមតែមួយដោយមានផលប្រយោជន៍រួម ការកំណត់វិសាលភាពនៃអង្គហេតុដែលត្រូវយកមកជំនុំជម្រះនៅដំណាក់កាលដំបូងនេះ.......ពុំមានផលប៉ះពាល់ទៅលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការទេ ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់ទៅនឹងការសម្រេចនេះ ៖

> ដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ បានប៉ះពាល់យ៉ាងច្បាស់ក្រឡែតចំពោះសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការដំណាក់ដំបូងនេះ នៅខណៈដែលការចូលរួមរបស់ពួកគេគឺត្រូវពឹងផ្អែកទៅលើការចង្អុលថា ជាផលវិបាកដោយផ្ទាល់នៃបទឧក្រិដ្ឋប្រឆាំងនឹងជនជាប់ចោទយ៉ាងហោចណាស់មួយ ដែលពួកគាត់បានទទួលរងព្យសនកម្មជាលក្ខណៈផ្លូវកាយសម្ភារៈ ឬផ្លូវចិត្ត ដែលបានទាមទារ ដោយផ្អែកលើសំណងផ្លូវចិត្ត និងសមូហភាព...... ។ សាលក្រមសំណុំរឿង០០១.....បានបញ្ជាក់ច្បាស់ណាស់ថា ដើម្បីអាចទទួលយកបាន

ដើមបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវបង្ហាញថា ការទទួលរងគ្រោះរបស់ពួកគេ គឺជាលទ្ធផលដោយផ្ទាល់បណ្តាលមកពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយជនជាប់ចោទ ។

ដោយសារសំណុំរឿង០០២/០១ ដោះស្រាយតែចំពោះបទឧក្រិដ្ឋមួយចំនួន ជាជាងគោលនយោបាយទូទាំងប្រទេសកម្ពុជា ដែលលើកឡើងដោយអង្គបុរេជំនុំជម្រះ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន អាចនឹងមិនត្រូវបានរាប់បញ្ចូលទៅក្នុងក្រុមរួមនោះទេ ។ ក្នុងចំណោមជនរងគ្រោះចំនួនជិត ៨០០០នាក់ ដែលបានចូលរួម គឺមានចំនួនត្រឹមតែ៧៥០នាក់ប៉ុណ្ណោះត្រូវបានទទួលយក ដោយសារមានការជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់ទាក់ទងនឹងការផ្លាស់ទីលំនៅដោយបង្ខំ ។ ទោះបីជាយ៉ាងណាក៏ដោយ ឋានៈគតិយុត្តនៃដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនដែលការទទួលរងការខូចខាតរបស់ពួកគេពុំមានជាប់ទាក់ទងទៅនឹងគោលនយោបាយ នៅពុំទាន់ត្រូវបានដោះស្រាយនៅឡើយទេ ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីភាពអាចទទួលយកបាន ទំនងក្លាយជាសេចក្តីសម្រេចចុងក្រោយ បើយោងទៅលើវិធានផ្ទៃក្នុង ហើយអង្គជំនុំជម្រះសាលាដំបូងក៏ពុំទាន់បានឆ្លើយតបទៅនឹងសំណើឲ្យមានការបញ្ជាក់ហេតុផលស្តីពីបញ្ហានេះដែរ ។

បញ្ហាចំបងគឺសិទ្ធិទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដោយសារការទទួលរងការខូចខាតពួកគេពុំជាប់ទាក់ទងនឹងអង្គហេតុដែលត្រូវលើកយកមកជំនុំជម្រះលើសំណុំរឿង០០២/០១ ។ វិធានផ្ទៃក្នុងកំរិតការផ្តល់សំណងមកត្រឹមជាការ ក) ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទដែលត្រូវបានផ្តន្ទាទោស និង ខ) ផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើង ការខូចខាតនេះ ។

ចាប់តាំងពីមានការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា សំណើទាមទារសំណងគួរតែឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ ដែលតម្រូវឲ្យមានភាពជាប់ទាក់ទងរវាងការខូតខាតដែលទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី និងបទឧក្រិដ្ឋដែលត្រូវបានផ្តន្ទាទោសនៅក្នុងសំណុំរឿង០០២/០១ ។ ហេតុដូច្នេះ ទើបបានជានៅក្នុងសាលដីកាក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ការផ្តល់សំណងគួរតែសមស្របនឹងវិធានការទាំងឡាយដែលផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះឲ្យបានច្រើនតាមដែលអាចច្រើនទៅបាន ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានប្រើប្រាស់ភាពវៃឆ្លាតរបស់ខ្លួនក្នុងការកំណត់ពីអាទិភាពនៃសំណង ដោយត្រូវតតាំងជាមួយភាពចាំបាច់ក្នុងការទាមទារសំណង ទាំងសំណងជាក់លាក់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងការខូចខាតនៅក្នុងសំណុំរឿង០០២/០១ និងពង្រីកចំនួនជនរងគ្រោះ ដោយរាប់បញ្ចូលទាំងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដែលការទទួលរងរបស់ពួកគេនឹងពុំមានលើកឡើងនៅក្នុងសំណុំរឿង០០២/០១ ។ ទោះបីជាការធ្វើឲ្យមានតុល្យភាពផលប្រយោជន៍ ផ្តល់ជូនអង្គជំនុំជម្រះនូវលទ្ធ

ភាពមួយចំនួនរួចផុតពីប្រតិកម្មតបចំពោះការបំបែកកិច្ចដំណើរការនីតិវិធីក៏ដោយ ក៏យ៉ាងហោចណាស់មានសំណាងមួយ(ក្នុងចំណោមសំណាងទាំងពីរដែលធ្លាប់ត្រូវបានផ្តល់នៅក្នុងសំណុំរឿង០០១) នឹងពុំអាចផ្តល់ជូនដូចអ្វីដែលបានអះអាងឡើយ គឺការដាក់ឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងសាលក្រម ។

ក្នុងអំឡុងពេលនៃសវនាការកាលពីសប្តាហ៍មុន ស្តីពីការពិចារណាលើផលវិបាកដែលកើតចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលុបចោលដីកាបំបែកកិច្ចដំណើរការនីតិវិធី ប្រហែលជាអាចនឹងកំហិតការពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ប៉ុន្តែប្រសិនបើគោលនយោបាយឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានចោទប្រកាន់មិនត្រូវបានលើកយកមកជំនុំជម្រះទេ បញ្ហាគឺនៅតែបន្តមានសម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដដែល ។ ដោយពុំដឹងថាតើនឹងត្រូវពន្យល់ទៅកូនក្តីរបស់ខ្លួនចំពោះភាពពុំជាប់ទាក់ទងដែលប៉ះពាល់ដល់ឋានៈស្របច្បាប់ក្នុងសំណុំរឿងដោយរបៀបណា និងថាតើត្រូវត្រៀមរៀបចំពន្យល់អំពីលទ្ធភាពដែលពួកគេទំនងជាពុំត្រូវបានទទួលស្គាល់ជាផ្លូវការ ដោយពុំត្រូវបានដាក់ឈ្មោះចូលក្នុងសេចក្តីសម្រេចចុងក្រោយតាមវិធីណាទេ ។ ដោយសារតែទាំងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តី សង្កត់ធ្ងន់ទៅលើផលវិបាកដែលកើតចេញពីដីកាបំបែកកិច្ចដំណើរការនីតិវិធីចំពោះឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីសម្រេចថ្មីរបស់អង្គជំនុំជម្រះស្តីពីវិសាលភាពនៃសំណុំរឿងនេះអាចរំពឹងថានឹងបញ្ចប់បញ្ហាដែលកំពុងតែចោទនេះ ។